ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបទីប្រឹក្សាគ្រប់គ្រង និងអភិវឌ្ឍន៍សកលមកពីប្រទេសជប៉ុន



នៅព្រឹកថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបលោក **O.Ishita** ទីប្រឹក្សាគ្រប់គ្រង និងអភិវឌ្ឍន៍សកលនៃប្រទេសជប៉ុន និងសហការី ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **O.Ishita** ទីប្រឹក្សាគ្រប់គ្រង និងអភិវឌ្ឍន៍សកលមកពីប្រទេសជប៉ុន និងសហការី បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សា គឺលោកបានដឹកនាំតំណាងក្រុមហ៊ុន Kett មកពីប្រទេសជប៉ុន ដើម្បីណែនាំពីផលិតផលមួយចំនួនរបស់ក្រុមហ៊ុន ដើម្បីធ្វើចរាចរណ៍លើទីផ្សារកម្ពុជា ។ ម៉ាស៊ីនទាំងនោះ មានម៉ាស៊ីនធ្វើតេស្តសំណើម លើផលិតផល

អង្ករ ដែលមានកិរិតស្តង់ដារ ISO712 –ម៉ាស៊ីនធ្វើតេស្តភាពសនៃអង្ករ C-600 និងម៉ាស៊ីនពិសោធកម្រាស់ស្រទាប់ អង្ករ ជាដើម ។ ក្រៅពីនោះ ក្រុមហ៊ុន Kett ក៏មាននាំចូលប្រភេទម៉ាស៊ីនធ្វើតេស្តគ្រាប់ធញ្ញជាតិដ៏ទៃទៀតផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសំដែងការស្វាគមន៍ និងចាត់ទុកការនាំចូលឧបករណ៍វាស់សំណើម អង្ករ និងឧបករណ៍ដ៏ទៃទៀតមកពីប្រទេសជប៉ុនដែលមានភាពល្បីល្បាញជាយូរមកហើយ ពិតជាសមស្របនិងស្ថានភាពនៃ ប្រទេសកម្ពុជា ដែលជាប្រទេសកសិកម្ម ហើយមានគោលនយោបាយនាំអង្ករចេញឱ្យបាន ១លានតោន នៅឆ្នាំ ២០១៥ នេះ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានជម្រាបថា តាមបទពិសោធន៍ម៉ាស៊ីនវាស់សំណើមនេះ គឺមាន អត្ថប្រយោជន៍ណាស់ ជាពិសេសគឺការបន្ថយភាពបាត់បង់ ស្រូវ–អង្ករ នៅដំណាក់កាលនីមួយៗ ដូចជា:ដំណាក់កាល ច្រូតកាត់–ដំណាក់កាលស្តុក–ដំណាក់កាលកិន និងប៉ូលា ជាដើម ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានរំលឹកថា: នៅកម្ពុជា ការប្រមូលផលស្រូវក្រោយរដូវច្រូតកាត់ គឺមានការបាត់បង់ ពី៥% ទៅ១៥% បើគិតជាទឹកប្រាក់អស់ជាច្រើនលានដុល្លា ក្នុងផលិតផលស្រូវ ផលិតបាននៅកម្ពុជា ប្រមាណ៦លានតោន ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី បានណែនាំថា: ការយកឧបករណ៍ខាងលើមកចែកចាយលើទីផ្សារកម្ពុជា សូមធ្វើការទំនាក់ ទំនងជាមួយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីមជ្ឈមណ្ឌលធ្វើព្យាសកម្ម ( Calibration ) ជាមុនសិន ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃឧបករណ៍ទាំងនោះ សម្រាប់ដាក់លក់ដល់អតិថិជន ។

ជាចុងក្រោយ ដៃគូសន្ទនាទាំងពីរ បានឯកភាពថានឹងបង្កើតឱ្យមានសិក្ខាសាលាមួយនាពេលខាងមុខ ក្រោម ការឧបត្ថម្ភដោយ ក្រុមហ៊ុន Kett និងរៀបចំដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីធ្វើការផ្សព្វផ្សាយដល់អ្នក ពាក់ព័ន្ធ ជាពិសេសម្ចាស់រោងម៉ាស៊ីនកិនស្រូវបានស្វែងយល់ពីផលប្រយោជន៍នៃឧបករណ៍ធ្វើតេស្តជាតិសំណើមអង្ករ និងឧបករណ៍ដ៏ទៃៗទៀត ។



ស្ថិតក្នុងឱកាសនោះផងដែរ តំណាងក្រុមហ៊ុន Kett ក៏បានប្រគល់ជូនឧបករណ៍វាស់ជាតិសំណើមអង្ករ ០១ គ្រឿង ជូនឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ សម្រាប់ទុកប្រើប្រាស់ ក្នុងមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។

